ទីស្តីការក្រសួងយុត្តិធម៌

លេខ ៨៨៧ រ.វ ខក្រ-៩៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរណែនាំ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**-លោកចាងហ្វាងសាលាឧទ្ធរណ៍**

**-លោកប្រធានតុលាការខេត្ត ក្រុង**

**-លោកប្រធានតុលាការយោធា**

**-លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**-លោកព្រះរាជអាជ្ញាអមតុលាការយោធា**

**សូមជ្រាប។**

**កម្មវត្ថុ:** ការណែនាំអំពីនីតិវិធីនៃការបញ្ជូនសំណុំរឿងដែលជាប់បណ្តឹងឧទ្ធរណ៍ នឹងបណ្តឹងសាទុក្ខ ។

**យោង:** មាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ។

ខ្ញុំសូមជម្រាបថា កន្លងមកក្រសួងបានទទួលបណ្តឹងជាច្រើនដែលម្ចាស់ឬណ្តឹងបានប្តឹងអំពីចៅក្រម នឹងក្រឡាបញ្ជីនៃតុលាការខេត្ត ក្រុង និងសាលាឧទ្ធរណ៍ថា មិនព្រមបញ្ជូនសំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍និងទៅតុលាការកំពូលឱ្យបានទាន់ពេលវេលា ។ សំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍ខ្លះតុលាការខេត្ត.ក្រុង បន្លាយពេលវេលាដល់ទៅជាងពីរឆ្នាំហើយនៅតែមិនទាន់បានបញ្ជូនទៅសាលាឧទ្ធរណ៍ទៀត ។

ដើម្បីជៀសវាងការបាត់បង់ផលប្រយោជន៍ដល់គូក្តី និងដើម្បីបញ្ចប់នូវការខ្វះខាតព្រមទាំងភាពខុសឆ្គងនេះ ក្រសួងសុំណែនាំ និងកំណត់ជាគោលការណ៍សម្រាប់តុលាការអយ្យការខេត្ត ក្រុង ព្រមទាំងសាលាឧទ្ធរណ៍អនុវត្តដូចតទៅ៖

ក-ចំពោះសំណុំរឿងដែលគូក្តីបានប្តឹងឧទ្ធរណ៍ហើយ ចៅក្រមនិងក្រឡាបញ្ជីនៃតុលាការខេត្ត.ក្រុង ត្រូវរៀបចំបែបបទចាត់បញ្ជូនសំណុំរឿងឧទ្ធរណ៍នោះទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល៦០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលចុះបណ្តឹងឧទ្ធរណ៍ ។

ខ-ចំពោះសំណុំរឿងដែលគូក្តីបានប្តឹងសាទុក្ខហើយចៅក្រម និងក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ត្រូវរៀបចំបែបបទចាត់បញ្ជូនសំណុំរឿងនោះ ទៅតុលាការកំពូល ក្នុងរយៈពេល ៦០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលចុះបញ្ជីងសាទុក្ខ ដូចករណីសំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍ដែរ ។

គ-ចំពោះសំណុំរឿងឧទ្ធរណ៍ពីបណ្តឹងដីកាកិច្ចការប្រញាប់ ចៅក្រម និងក្រឡាបញ្ជីនៃតុលាការខេត្ត ក្រុង និងសាលាឧទ្ធរណ៍ត្រូវរៀបចំបែបបទចាត់បញ្ជូនសំណុំរឿងនោះទៅសាលាឧទ្ធរណ៍ ឬទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃ យ៉ាងយូរ បន្ទាប់ពីទទួលបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ ។

ឃ-ចំពោះសំណុំរឿងឧទ្ធរណ៍ពីបណ្តឹងដីកាតម្កល់រឿងទុកចិត្តមិនចាត់ការ របស់ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ក៏ត្រូវតុលាការខេត្ត ក្រុង រៀបចំបែបបទបញ្ជូនទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលបណ្តឹងរួចហើយ ។

អំណើះតទៅ បើលោកចៅក្រម ឬក្រឡាបញ្ជី រូបណាមិនអនុវត្តតាមសារាចរណែនាំនេះឱ្យបានហ្មត់ចត់ទេ ក្រសួងនឹងចាត់វិធានការដាក់វិន័យរដ្ឋបាលយ៉ាងតឹងរឹងបំផុត ដោយមិនគិតដល់ការខូចខាតនូវផលប្រយោជន៍របស់គូក្តីផងទេ ប្រសិនបើមាន ។

ក្រោយពីបានទទួលសារាចរណែនាំនេះ សូមលោកប្រធានតុលាការគ្រប់ជាន់ថ្នាក់ប្រជុំផ្សព្វផ្សាយដល់មន្ត្រីរាជការទាំងអស់តាមអង្គភាពរៀងខ្លួនៗអំពីខ្លឹមសារនៃសារាចរនេះឱ្យបានជ្រាបគ្រប់ៗគ្នាដើម្បីអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពខ្ពស់តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ប្រធានតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

ដើម្បីជ្រាប និងអនុវត្ត